ISSR អ៊ិនធើណេសិនណល ស្គូល អហ្វ សៀមរាប International School of Siem Reap

# ព្រឹត្តិបត្រព័ត៌មាន លេខ៖ ០១

**ឆ្នាំសិក្សា ២០២២-២៣ ផ្នែកបឋមសិក្សាអន្តរជាតិ**




## សូមគោរពលោក លោកស្រី ដែលជាមាតា បិតា ឬអ្នកអាណាព្យាបាលសិស្សានុសិស្សទាំងអស់ជាទីគោរព

សូមលោក លោកស្រីរីករាយជាមួយព្រឹត្តិបត្រព័ត៌មានប្រចាំសប្តាហ៍ទី១ ក្នុងឆ្នាំសិក្សាថ្មី២០២២-២៣ ផ្នែកបឋមសិក្សាដែលលោកនាយក និងផ្នែករដ្ឋបាលសាលានឹងរៀបចំផ្ញើជូនលោក លោកស្រីជាប្រចាំ តាមរយៈកូនៗសិស្សានុសិស្ស។ លោកលោកស្រីអាចសួររកព្រិត្តិបត្តិព័ត៌មានពីកូន ឬក៏អាចយកពីកាបូបរៀនរបស់ពួកគេ ហើយព្រិត្តិបត្រព័ត៌មាននេះនឹងផ្សព្វផ្សាយលើទំព័រហ្វេសប៊ុក កម្មវិធីក្លាស់ដូចូ (Class Dojo) តេលេក្រាម និងគេហៈទំព័ររបស់សាលាផងដែរ។

យើងខ្ញុំសូមលើកទឹកចិត្តលោក លោកស្រីសូមឲ្យមានទំនាក់ទំនងជាមួយគ្រូបន្ទុកថ្នាក់ជិតស្និត ក្នុងករណីមានបញ្ហាណាមួយ ទោះបីតិចតួចក្តីក៏ត្រូវតែដោះស្រាយឲ្យបានឆាប់រហ័ស។ នៅចុងសប្តាហ៍ទី១ក្នុងខែកញ្ញា សាលានឹងរៀបចំជំនួបប្រជុំរវាងមាតា បិតាសិស្ស និងលោកគ្រូ អ្នកគ្រូបន្ទុកថ្នាក់ដើម្បីបង្កឱកាសមួយបានស្គាល់គ្នាទៅវិញទៅមក និងបានស្វែងយល់អំពីបទបញ្ញត្តិក្នុងថ្នាក់រៀនរបស់សិស្សផងដែរ។

មួយសប្តាហ៍ដំបូងនេះដំណើរការរៀនសូត្រប្រព្រឹត្តិទៅបានយ៉ាងរលូន សិស្សានុសិស្សស្លៀកពាក់ស្អាតបាត ពោរពេញដោយភាពរីករាយដែលបានឡើងថ្នាក់នៅឆ្នាំសិក្សាថ្មី ជាវប្បធម៌ល្អមួយដែលយើងត្រូវតែខិតខំបន្តទៅទៀត។ យើងខ្ញុំមានជំនឿយ៉ាងមុតមាំទៅលើទំនាក់ទំនងល្អរវាងសិស្ស គ្រូ និងអ្នកអាណាព្យាបាលសិស្ស ដែលជាគន្លឹះដ៏ជោគជ័យមួយសម្រាប់សាលាយើងទាំងអស់គ្នា។ យើងនឹងខិតខំរៀបចំអ្វីៗឲ្យបានល្អតាមតែអាចធ្វើទៅបានដើម្បីសិស្សានុសិស្សរបស់យើង។ លោកគ្រូ អ្នកគ្រូនឹងផ្ញើសារតាមរយៈEmail ឬកម្មវិធីClass Dojo ជូនលោក លោកស្រីដើម្បីជ្រាបជាព័ត៌មានពីសកម្មភាពដែលពួកគេបានសិក្សានៅក្នុងថ្នាក់រៀន ព្រមទាំងសកម្មភាពសិក្សាក្រៅថ្នាក់ផងដែរ។

ឆ្នាំសិក្សានេះសាលាក៏បានទទួលលោកគ្រូ អ្នកគ្រូថ្មីដែលជ្រើសរើសមកបម្រើការងារផងដែរ៖ យើងខ្ញុំសង្ឃឹមថាពួកគាត់នឹងមិនត្រឹមតែផ្តល់ជូនចំណេះដឹង បរិយាកាសសិក្សាតែប៉ុណ្ណោះទេ ពួកគាត់នឹងជួយសិស្សានុសិស្សរបស់យើងឲ្យកាន់តែរីកចំរើនលូតលាស់ ក្លាយជាអ្នកសិក្សាពេញមួយជីវិត។

នៅត្រីមាសនេះ សាលានឹងរៀបចំកិច្ចប្រជុំជាទៀងទាត់ជាមួយលោកគ្រូ អ្នកគ្រូជាប្រចាំដើម្បីពិនិត្យតាមដាននូវអ្វីដែលបានធ្វើ និងឆ្លុះបញ្ចាំងពីវឌ្ឍនភាពដែលសាលាបានអនុវត្ត និងចំនុចដែលត្រូវកែលម្អរឡើងវិញ។ មិនតែប៉ុណ្ណោះសាលានឹងរៀបចំការស្ទង់មតិ យោបល់ពីមាតា បិតាសិស្ស និងបន្តការផ្តល់ព័ត៌មានជូនលោក លោកស្រីប្រសិនបើមានអ្វីដែលត្រូវផ្លាស់ប្តូរ។

ខ្ញុំ និងលោកគ្រូ អ្នកគ្រូទាំងអស់នៅសាលាISSR ធ្វើការដោយក្តីរីករាយជាមួយនឹងការបង្ហាត់បង្រៀនកូនៗសិស្សានុសិស្ស ព្រមទាំងជួយដោះស្រាយបញ្ហាប្រឈមនានារបស់ពួកគេ។

យើងខ្ញុំដឹងថារយៈពេល ២ឆ្នាំចុងក្រោយនេះ លោក លោកស្រីមានផលលំបាកជាច្រើន ទាំងលោក លោកស្រីដែលរស់នៅក្នុងខេត្តសៀមរាប និងក្រៅខេត្ត ម្យ៉ាងវិញទៀត ប្រសិន លោក លោកស្រីផ្លាស់ប្តូរទីលំនៅ លេខទំនាក់ទំនងថ្មី សូមជួយផ្តល់ដំណឹងមកការិយាល័យរដ្ឋបាល។ ករណីមានបញ្ហាណាមួយកើតឡើង យើងខ្ញុំមានយន្តការច្បាស់លាស់ដើម្បីអនុវត្ត និងរក្សាសុវត្ថិភាពដល់កូនរបស់លោក លោកស្រី ដែលជាក្តីបារម្ភដ៏ចម្បងរបស់សាលាផងដែរ។

ចំពោះលោក លោកស្រីដែលមានគម្រោងធ្វើដំណើរទៅក្រៅខេត្ត ឬក្រៅប្រទេស និងមានបំណងសុំច្បាប់ឲ្យកូនៗ សូមពិនិត្យមើលប្រតិទិនប្រចាំឆ្នាំរបស់សាលា។ ប្រសិនបើកូនៗ មិនស្រួលខ្លួន ឬមានជំងឺសូមជួយផ្តល់ព័ត៌មានមកការិយាល័យរដ្ឋបាល។ យើងខ្ញុំសង្ឃឹមថា លោក លោកស្រី និងកូនៗសិស្សានុសិស្សនឹងរីករាយជាមួយនឹងការទំនាក់ទំនងជាមួយសាលា។ យើងខ្ញុំតែងតែបើកចំហរដោយភាពស្មោះត្រង់ដោយលោកស្រីអាចផ្តល់ព័ត៌មានតាមទូរស័ព្ទប្រសិនបើករណីនៅឆ្ងាយពីសាលា។

សូមអរគុណ!

David C Key

នាយកប្រតិបត្តិកម្មវិធីអន្តរជាតិផ្នែកបឋម

## លោកគ្រូ អ្នកគ្រូចូលបម្រើការងារថ្មី



ជម្រាបសួរ! នាងខ្ញុំឈ្មោះ Claire Wilson ជាគ្រូបង្រៀនថ្នាក់ទី៤ខថ្មី នៅសាលាISSRផ្នែកបឋម។ កម្រិតវប្បធម៌គឺនាងខ្ញុំបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រនៅសាកលវិទ្យាល័យ NHL Stenden ប្រទេសហូឡង់ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការបង្ហាត់បង្រៀន។នាងខ្ញុំរីករាយដែលបានបម្រើការងារនៅទីនេះ និងរង់ចាំស្វាគមន៍លោក លោកស្រីទាំងអស់គ្នា!



ជម្រាបសួរ! នាងខ្ញុំមានឈ្មោះ Kira ជាគ្រូបង្រៀនផ្នែកហែលទឹកថ្មីប្រចាំសាលាISSRផ្នែកបឋម។ នាងខ្ញុំបង្រៀនមុខវិជ្ជាកីឡា ទាំងផ្នែកបឋម និងផ្នែកវិទ្យាល័យជួយ លោកគ្រូTony ។ នាងខ្ញុំក៏ជាគ្រូបង្រៀនជំនួយមុខវិជ្ជាភាសាអង់គ្លេសជាមួយអ្នកគ្រូElla នៅផ្នែកបឋមផងដែរ។ ចំពោះបទពិសោធន៍ការងារវិញ នាងខ្ញុំធ្លាប់បង្រៀនហែលទឹក និងសង្គ្រោះអ្នកលង់ទឹកតាំងពីឆ្នាំ២០១៦ និងជាគ្រូបង្រៀនភាសាអង់គ្លេស(ELS)ចាប់ពីឆ្នាំ២០២០។ នាងខ្ញុំមកពីប្រទេសអាឡឺម៉ង់និងប្រទេសអាមេរិក។ សូមអរគុណ!



ជម្រាបសួរ! នាងខ្ញុំឈ្មោះ Sally-Anne ជាគ្រូបង្រៀនថ្នាក់មត្តេយ្យកម្រិតខ្ពស់(Rec.2)និងជាប្រធានក្រុមបច្ចេកទេសកម្រិតមត្តេយ្យ។ នាងខ្ញុំមានបទពិសោធន៍បង្រៀនកម្រិតមត្តេយ្យ និងបឋមសិក្សានៅសាលាអន្តរជាតិជាច្រើនឆ្នាំ។



ជម្រាបសួរ! នាងខ្ញុំឈ្មោះ Mélanie Boyer ជាគ្រូបង្រៀនថ្នាក់ទី២ថ្មី នៅសាលាISSR។ នាងខ្ញុំមានបទពិសោធន៍បង្រៀនផ្នែកបឋមសិក្សា និងភាសារយៈពេល៦ឆ្នាំ នៅសាលាអន្តរជាតិជាច្រើន។

## រចនាសម្ព័ន្ធគ្រប់គ្រងបឋមសិក្សា ផ្នែកភាសាអង់គ្លេស

### 1. នាយកប្រតិបត្តិកម្មវិធីសិក្សា



លោក **David Key**

មុនពេលមកបំពេញការងារនៅសាលាដ៏អស្ចារ្យនេះ ខ្ញុំបានមានឱកាសលើកកម្ពស់សមត្ថភាព និងបញ្ញារបស់ខ្ញុំអំពីការបង្រៀន និងការរៀនជាមួយវប្បធម៌ដ៏សម្បូរបែបនៅទូទាំងពិភពលោក។ ដំបូងនៅប្រទេសអូស្ត្រាលី រហូតដល់ប្រទេសអង់គ្លេស បន្ទាប់មកគឺអេហ្ស៊ីប តង់ហ្សានី និងអារ៉ាប់រួម។ ចំពោះប្រទេសក្នុងទ្វីបអាស៊ី ធ្លាប់ជានាយកសាលានៅសាធារណៈរដ្ឋកូរ៉េខាងត្បូង ចិន ម៉ាល់ឌីវ ប៉ាគីស្ថាន ម៉ាឡេស៊ី និងចុងក្រោយកាហ្សាក់ស្ថាន សាលានីមួយៗនាំមកនូវតម្លៃ និងតម្រូវការអប់រំរៀងៗខ្លួន។ ប្រទេសទាំងនោះបានផ្តល់បទពិសោធន៍ផ្សេងៗគ្នា ដែលបានពង្រឹងការអភិវឌ្ឍន៍របស់ខ្ញុំក្នុងនាមជាអ្នកសិក្សាពេញមួយជីវិត និងជាអ្នកដោះស្រាយបញ្ហាប្រកបដោយភាពច្នៃប្រឌិត។

អ្វីដែលសាលា ISSR ចង់បានគឺការអប់រំសិស្សឲ្យយល់តម្លៃនៃការរៀនសូត្រពេញមួយជីវិត ដើម្បីស្វែងរកអនាគតដ៏ត្រចះត្រចង់ប្រកបដោយនិរន្តរភាពសម្រាប់មនុស្សជំនាន់ក្រោយ។

### 2. ក្រុមបច្ចេកទេសផ្នែកបឋមសិក្សា(ទី៤-ទី៦)

**សមាជិកក្នុងក្រុម**



អ្នកគ្រូ Dimple
ថ្នាក់ទី៥A



អ្នកគ្រូ Gloria
ថ្នាក់ទី៦



អ្នកគ្រូ Claire
ថ្នាក់ទី៥B



អ្នកគ្រូ Heather
ថ្នាក់ទី៤

3. ក្រុមបច្ចេកទេសផ្នែកបឋមសិក្សា(ទី១-ទី៣) សមាជិកក្នុងក្រុម



លោកគ្រូ Philip
ថ្នាក់ទី៣



អ្នកគ្រូ Mélanie
ថ្នាក់ទី២



អ្នកគ្រូ Katie
ថ្នាក់ទី១B



អ្នកគ្រូ Caryl
ថ្នាក់ទី១A

4. ក្រុមបច្ចេកទេសផ្នែកមត្តេយ្យ សមាជិកក្នុងក្រុម



អ្នកគ្រូ Sallyanne
ថ្នាក់មត្តេយ្យកម្រិតខ្ពស់(Rec.2)



អ្នកគ្រូ Rita
ថ្នាក់មត្តេយ្យកម្រិតទាប(Nursery)



អ្នកគ្រូ Janica
ថ្នាក់មត្តេយ្យកម្រិតមធ្យម


# I.S.S.R

We are One, But We are Many!

**អាសយដ្ឋាន**

ផ្លូវក្រវ៉ាត់ក្រុង, ភូមិកក្រាញ់, សង្កាត់សៀមរាប, ក្រុងសៀមរាប, ខេត្តសៀមរាប

ទូរស័ព្ទលេខ: (+៨៥៥) (0) ១២ ៨៧ ៨៧ ៨២ | (+៨៥៥)(0) ៨១ ៨៧ ៨៧ ៨២

Email: admin@issr.edu.kh Webiste: www.issr.edu.kh